សេចក្ដីជូនដំណឹង
អំពីព័ត៌មាន
អ្នកបោះ
ឆ្នោតផ្លូវការ

# សេចក្ដីជូនដំណឹង ទាក់ទងនឹងការហាមឃាត់ចំពោះការឃោសនារកសំឡេងឆ្នោត និងអំពើពុករលួយក្នុងដំណើរការបោះឆ្នោត

## ការព្រមាន៖ ការឃោសនារកសំឡេងឆ្នោតត្រូវបានហាមឃាត់ !

ការបំពាននឹងអាចឈានទៅដល់ការផាកពិន័យ និង/ឬការជាប់ពន្ធនាគារ។

### ទីកន្លែង៖

- នៅក្នុងបរិវេណក្បែរទៅនឹងបុគ្គលដែលតម្រង់ជួរដើម្បីទម្លាក់សន្លឹកឆ្នោត ឬនៅក្នុងបរិវេណ 100 ហ្វីតនៃច្រកចូលនៃកន្លែងបោះឆ្នោត កន្លែងបោះឆ្នោតជាយផ្លូវ ឬប្រអប់ទម្លាក់សន្លឹកឆ្នោតដែលសកម្មភាពទាំងឡាយខាងក្រោមត្រូវបានហាមឃាត់ ។



### សកម្មភាពទាំងឡាយដែលត្រូវបានហាមឃាត់៖

- **មិនត្រូវ** ស្នើសុំឱ្យបុគ្គលបោះឆ្នោតឱ្យ ឬប្រឆាំងនឹងបេក្ខជនណាម្នាក់ ឬវិធានសន្លឹកឆ្នោតនោះទេ ។
- **មិនត្រូវ** បង្ហាញឈ្មោះ និមិត្តសញ្ញា ឬរូបភាពរបស់បេក្ខជននោះទេ ។
- **មិនត្រូវ** រារាំងការចូលប្រើប្រាស់ ឬដើរវារែកនៅក្បែរប្រអប់ទម្លាក់សន្លឹកឆ្នោតនោះទេ ។
- **មិនត្រូវ** ផ្តល់ឯកសារ ឬព័ត៌មានជាសំឡេងណាមួយសម្រាប់ ឬប្រឆាំងនឹងបេក្ខជនណាមួយ ឬវិធានសន្លឹកឆ្នោតនៅក្បែរកន្លែងបោះឆ្នោត មណ្ឌលបោះឆ្នោត ឬប្រអប់ទម្លាក់សន្លឹកឆ្នោតនោះទេ ។
- **មិនត្រូវ** ចែកចាយញត្តិទាំងឡាយ រួមបញ្ចូលទាំងសកម្មភាពផ្តួចផ្តើម ការធ្វើប្រជាមតិ ការបោះឆ្នោតដកតំណែង ឬការតែងតាំងបេក្ខជនណាមួយនោះទេ ។
- **មិនត្រូវ** ចែកចាយ បង្ហាញ ពាក់សម្លៀកបំពាក់ណាមួយ (មួក អាវ សញ្ញា ខ្សែ ស្ទីគ័រ) ដែលមានឈ្មោះ រូបភាព និមិត្តសញ្ញារបស់បេក្ខជន និង/ឬគាំទ្រ ឬប្រឆាំងនឹងបេក្ខជនណាម្នាក់ ឬវិធានសន្លឹកឆ្នោតនោះទេ។
- **មិនត្រូវ** បង្ហាញព័ត៌មាន ឬនិយាយទៅអ្នកបោះឆ្នោតអំពីសិទ្ធិបោះឆ្នោតរបស់អ្នកបោះឆ្នោតនោះទេ ។

សេចក្តីសង្ខេបនៃការហាមឃាត់ចំពោះការឃោសនារកសំឡេងឆ្នោតខាងលើមានចែងនៅក្នុងមាត្រា 7 ជំពូក 4 ផ្នែក 18 នៃក្រមបោះឆ្នោតនៃរដ្ឋកាលីហ្វ័រញ៉ា។

## ការព្រមាន៖ ការប្រព្រឹត្តអំពើពុករលួយក្នុងដំណើរការបោះឆ្នោតត្រូវបានហាមឃាត់ !

អ្នកដែលបំពាននឹងទទួលរងការពិន័យ និង/ឬ ការជាប់ពន្ធនាគារ។

### សកម្មភាពទាំងឡាយដែលត្រូវបានហាមឃាត់៖

- **មិនត្រូវ** ប្រព្រឹត្តិ ឬមានបំណងប្រព្រឹត្តិអំពើបន្លំក្នុងការបោះឆ្នោត ។
- **មិនត្រូវ** ផ្តល់ប្រភេទនៃសំណង ឬការសូកប៉ាន់ណាមួយ នៅក្នុងទម្រង់ណាមួយ ឬដោយមធ្យោបាយណាមួយជាការបញ្ចុះបញ្ចូល ឬក្នុងបំណងបញ្ចុះបញ្ចូល ទៅដល់បុគ្គលណាម្នាក់ដើម្បីបោះឆ្នោត ឬមិនឱ្យធ្វើការបោះឆ្នោត។
- **មិនត្រូវ** បោះឆ្នោតដោយខុសច្បាប់ ។
- **មិនត្រូវ** ប៉ុនប៉ងធ្វើការបោះឆ្នោត ឬផ្តល់ការឧបត្ថម្ភដល់អ្នកដទៃទៀតឱ្យធ្វើការបោះឆ្នោតនៅពេលមិនមានសិទ្ធិក្នុងការបោះឆ្នោត ។
- **មិនត្រូវ** ចូលរួមក្នុងយុទ្ធនាការឃោសនាទាក់ទាញរកសំឡេងឆ្នោតថតរូប ឬកត់ត្រាអ្នកបោះឆ្នោតដែលចូលទៅកាន់ ឬចេញពីទីតាំងមណ្ឌលបោះឆ្នោតឬរារាំងសកម្មភាពចេញចូលឬចតរថយន្តនោះទេ។
- **មិនត្រូវ** បង្កផលវិបាកដល់សិទ្ធិបោះឆ្នោតរបស់នរណាម្នាក់ ឬរារាំងនរណាម្នាក់មិនឱ្យធ្វើការបោះឆ្នោត ពន្យារដំណើរការបោះឆ្នោត ឬការផ្តល់យោបល់ដោយការបោកបន្លំដល់បុគ្គលណាមួយថាគាត់មិនមានសិទ្ធិក្នុងការបោះឆ្នោត ឬថាគាត់មិនបានចុះឈ្មោះបោះឆ្នោតឡើយ ។
- **មិនត្រូវ** ប៉ុនប៉ងពិនិត្យបញ្ជាក់រកមើលពីរបៀបដែលអ្នកបោះឆ្នោតធ្វើការបោះឆ្នោតនោះទេ ។
- **មិនត្រូវ** កាន់កាប់ ឬរៀបចំឱ្យនរណាម្នាក់កាន់កាប់អាវុធនៅក្នុងបរិវេណនៃកន្លែងបោះឆ្នោត លើកលែងតែក្នុងករណីមួយចំនួន
- **មិនត្រូវ** បង្ហាញខ្លួន ឬរៀបចំឱ្យនរណាម្នាក់បង្ហាញខ្លួនក្នុងឯកសណ្ឋានជាមន្ត្រីរៀបចំសុវត្ថិភាព សន្តិសុខ ឬបុគ្គលិកសន្តិសុខនៅក្នុងបរិវេណនៃកន្លែងបោះឆ្នោត លើកលែងតែក្នុងករណីមួយចំនួន ។
- **មិនត្រូវ** ប៉ះពាល់ ឬជ្រៀតជ្រែកជាមួយនឹងសមាសធាតុណាមួយនៃប្រព័ន្ធបោះឆ្នោតនោះទេ ។
- **មិនត្រូវ** ក្លែង បន្លំ ឬប៉ះពាល់ទៅលើសន្លឹកឆ្នោតដែលបញ្ជូនត្រលប់មកវិញនោះទេ ។
- **មិនត្រូវ** កែប្រែសន្លឹកឆ្នោតដែលបញ្ជូនត្រលប់មកវិញនោះទេ ។
- **មិនត្រូវ** ប៉ះពាល់ បំផ្លាញ ឬកែប្រែបញ្ជីបោះឆ្នោតណាមួយ សន្លឹកឆ្នោតផ្លូវការ ឬប្រអប់ដាក់សន្លឹកឆ្នោតនោះទេ ។
- **មិនត្រូវ** បង្ហាញប្រអប់ប្រមូលសន្លឹកឆ្នោតមិនផ្លូវការណាមួយដែលអាចបោកបញ្ឆោតអ្នកបោះឆ្នោតឱ្យជឿថាវាជាប្រអប់ប្រមូលសន្លឹកឆ្នោតផ្លូវការនោះទេ ។
- **មិនត្រូវ** ប៉ះពាល់ ឬជ្រៀតជ្រែកលើច្បាប់ចតចម្លងនៃលទ្ធផលនៃការបោះឆ្នោតនោះទេ ។
- **មិនត្រូវ** បង្ខំ ឬបោកបញ្ឆោតនរណាម្នាក់ដែលមិនចេះអក្សរ ឬមនុស្សចាស់ឱ្យធ្វើការបោះឆ្នោតឱ្យ ឬប្រឆាំងនឹងបេក្ខជនណាម្នាក់ ឬវិធានដែលផ្ទុយទៅនឹងគោលបំណងរបស់ពួកគេនោះទេ ។
- **មិនត្រូវ** ដើរតួជាមន្ត្រីបោះឆ្នោតនៅពេលអ្នកមិនមែនជាមន្ត្រីបោះឆ្នោតនោះទេ ។

**និយោជក** មិនអាចទាមទារ ឬស្នើឱ្យបុគ្គលិករបស់ខ្លួននាំយកសន្លឹកឆ្នោតបោះតាមប្រអប់សំបុត្ររបស់ខ្លួនមកកន្លែងធ្វើការ ឬស្នើឱ្យបុគ្គលិករបស់ខ្លួនបោះឆ្នោតនៅកន្លែងធ្វើការនោះទេ ។ នៅពេលបើកប្រាក់បៀវត្ស ឬប្រាក់ឈ្នួល និយោជកមិនអាចភ្ជាប់ឯកសារផ្សេងៗដែលមានបំណងជះឥទ្ធិពលដល់ទស្សនៈ ឬសកម្មភាពនយោបាយរបស់និយោជិតខ្លួននោះទេ ។

**សមាជិកក្រុមប្រឹក្សាប្រចាំមណ្ឌល** មិនអាចប៉ុនប៉ងកំណត់ពីរបៀបដែលអ្នកបោះឆ្នោតធ្វើការបោះឆ្នោតនោះទេ ឬប្រសិនបើព័ត៌មាននោះត្រូវបានបើកបង្ហាញ សូមបង្ហាញពីរបៀបដែលអ្នកបោះឆ្នោតទម្លាក់សន្លឹកឆ្នោតរបស់ខ្លួន ។

ការហាមឃាត់លើសកម្មភាពដែលទាក់ទងនឹងអំពើពុករលួយក្នុងដំណើរការបោះឆ្នោតដែលត្រូវបានសង្ខេបខាងលើមានចែងនៅក្នុងជំពូក 6 ផ្នែក 18 នៃក្រមបោះឆ្នោតនៃរដ្ឋកាលីហ្វ័រញ៉ា។

Khmer